

# មានការធានារ៉ាប់រងសុខភាពរួចហើយ?

ប្រសិនបើអ្នកកំពុងមានការធានារ៉ាប់រងសុខភាពរួចហើយតាមរយៈ: សុខភាពផ្លែប៉ោមសម្រាប់កូនៗ (Apple Health for Kids) (ក៏ត្រូវបានស្គាល់ផងដែរជាមេឌីខេដ (Medicaid) ឬ CHIP) អ្នកត្រូវការបន្តជាថ្មីនូវការធានារ៉ាប់រងរបស់អ្នកដើម្បីរក្សាវា ។

ដំណើរការបន្តជាថ្មីគឺមានភាពខុសគ្នាជាងនៅពេលអតីតកាល៖

- ប្រសិនបើអ្នកមានអាយុចាប់ពី 19 ឆ្នាំឡើងទៅ អ្នកអាចបន្តជាថ្មីដោយ ការទៅកាន់គេហទំព័រ អ្នកស្វែងរកផែនការសុខភាព (Healthplanfinder) **www.wahealthplanfinder.org** ថ្មី ។ មើលខាងក្នុងសម្រាប់ព័ត៌មានលម្អិត ។
- ប្រសិនបើអ្នកមានអាយុចាប់ពី 18 ឡើងទៅ ហើយកំពុងដាក់ពាក្យសុំ ដោយខ្លួនឯង អ្នកអាចដាក់ពាក្យ ឬបន្តជាថ្មីប៉ុណ្ណោះដោយហៅទៅ លេខ 1-855-923-4633 ឬ ជាមួយជំនួយពីនរណាម្នាក់នៅក្នុង សហគមន៍របស់អ្នក ។ ដើម្បីស្វែងរកអ្នកជួយ/អ្នកស្ទង់មើលទិស ដោយផ្ទាល់ផ្អែកលើសហគមន៍ ចូលទៅកាន់គេហទំព័រ អ្នកស្វែងរកផែនការសុខភាព (Healthplanfinder) **www.wahealthplanfinder.org** ។




អាជ្ញាធរថែទាំសុខភាពចាត់ចែងសុខភាពផ្លែប៉ោមវ៉ាស៊ីងតោន Washington Apple Health (Medicaid) (មេឌីខេដ) ។

ប្រសិនបើអ្នកមានសំណួរនានាអំពីការធានារ៉ាប់រងនេះ សូមហៅទៅកាន់លេខ 1-800-562-3022 ។ អ្នកប្រើ TTY/TDD ហៅទៅកាន់លេខ 1-800-848-5429 ។

Washington State Health Care Authority

HCA 19-023 CA (02/14)

Washington Apple Health

# តើអ្នកត្រូវការការថែទាំឥតគិតថ្លៃ ឬដោយតម្លៃទាបដែរទេ?

យើងផ្ដល់ឱ្យអ្នកមានការធានារ៉ាប់រង



អ្វីដែលយុវវ័យ និងយុវជនវ័យក្មេងត្រូវតែដឹងអំពី

**សុខភាពផ្លែប៉ោមវ៉ាស៊ីងតោន (Washington Apple Health)**

# តើខ្ញុំទទួលបានការថែទាំឥតគិតថ្លៃ ឬដោយតម្លៃទាបដែរទេ?

តើអ្នកបានដឹងថា យុវវ័យ និងយុវជនវ័យក្មេងជាច្រើនក្នុង រដ្ឋវ៉ាស៊ីងតោនអាចទទួលបានការថែទាំសុខភាពឥតគិតថ្លៃ ឬដោយ តម្លៃទាបដែរទេ?

វាមានឈ្មោះថាសុខភាពផ្លែប៉ោមវ៉ាស៊ីងតោន ហើយវាប្រហែលជា (Washington Apple Health) ត្រឹមត្រូវសម្រាប់អ្នក ។

## ហេតុអ្វីបានជាខ្ញុំត្រូវការការធានារ៉ាប់រងសុខភាព?

ការធានារ៉ាប់រងសុខភាពអាចជួយជាមួយការថែទាំមូលដ្ឋាន មនុស្សវ័យក្មេងត្រូវការ ដូចជា ការទៅជួបពិនិត្យជាមួយវេជ្ជបណ្ឌិត ប្រសិនបើអ្នកមានជម្ងឺ ឬ រងរបួស ការពិនិត្យមើល STI ថ្នាំវេជ្ជបញ្ជា និង ការចូលសម្រាកនៅមន្ទីរពេទ្យ ។

ការធានារ៉ាប់រងសុខភាពក៏រាប់បញ្ចូលទាំងការបង្ការមិនឱ្យមានកូន ការថែទាំផ្ទៃពោះ ឬ ការបញ្ចប់ផ្ទៃពោះ និងសុខភាពផ្លូវចិត្ត និងការព្យាបាលការប្រើប្រាស់សារធាតុញៀន ។



# តើការធានារ៉ាប់រងសុខភាពនឹងគិតថ្លៃដែរទេ?

អាស្រ័យលើប្រាក់ចំណូលរបស់អ្នក អ្នកប្រហែលជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការធានាឥតគិតថ្លៃ ឬដោយតម្លៃទាប ។

## តើខ្ញុំអាចទទួលបានការធានារ៉ាប់រងសុខភាពដែរទេ ប្រសិនបើខ្ញុំមាន 19 អាយុ ឬលើសនេះ?

បាទ/ចាស! មានជម្រើសថ្មីៗសម្រាប់ការធានារ៉ាប់រងសុខភាពដែលអាចលៃលកបានសម្រាប់មនុស្សពេញវ័យ ។ នេះមានន័យថា មនុស្សពេញវ័យដែលមានប្រាក់ចំណូលទាប ហើយយុវជនវ័យក្មេងដែលស្ថិតនៅក្នុងការថែទាំជាកូនចិញ្ចឹមប្រហែលជាអាចមានសិទ្ធិទទួលបានការធានារ៉ាប់រងដោយឥតគិតថ្លៃ ។

## តើខ្ញុំអាចទទួលការធានារ៉ាប់រងសុខភាពដោយមិនចាំបាច់ឪពុកម្តាយរបស់ខ្ញុំបានទេ?

បាទ/ចាស! ជាធម្មតាយុវវ័យដែលមានអាយុ 18 ឆ្នាំ ឬក្មេងជាងនេះដាក់ពាក្យសុំការធានារ៉ាប់រងសុខភាពជាមួយឪពុកម្តាយរបស់ពួកគេ ឬអាណាព្យាបាល ។ ប៉ុន្តែ អ្នកប្រហែលជាអាចទទួលបានការធានារ៉ាប់រងសុខភាពដោយខ្លួនអ្នកផ្ទាល់ ប្រសិនបើអ្នក៖

- រស់នៅដោយឡែកពីឪពុកម្តាយ/អាណាព្យាបាលរបស់អ្នក ហើយមិនត្រូវបានទាមទារដោយពួកគេជាអ្នកទទួលបន្ទុកពន្ធឡើយ ។
- ជាស្រ្តីមានផ្ទៃពោះ ។
- ត្រូវការការគ្រប់គ្រងកំណើត ឬ ការថែទាំឆ្លងរោគដែលបញ្ជូនតាមការរួមភេទ ។

ប្រសិនបើអ្នកមានសំណួរនានា ឬគិតថាអ្នកប្រហែលជាស្ថិតក្នុងស្ថានភាពមួយក្នុងចំនោមទាំងនេះ ចូរទាក់ទងបណ្តាញ ទាន់ហេតុការណ៍សម្ងាត់ដោយឥតគិតថ្លៃតាមលេខ 1-855-WAFINDER (855-923-4633) និង និយាយថា៖
"ខ្ញុំត្រូវការពិភាក្សាជាមួយបុគ្គលិកអាចទទួលបានសិទ្ធិមេឌីខេដ។"
ពួកគេនឹងដាក់អ្នកទៅកាន់នរណាម្នាក់ដែលអាចជួយអ្នកឱ្យយល់ពីជម្រើសរបស់អ្នក ។

Washington Apple Health

# តើខ្ញុំត្រូវដាក់ពាក្យនៅពេលណា និងដោយរបៀបណា?

អ្នកអាចដាក់ពាក្យសុំការធានារាប់រងនៅពេលណាមួយដោយ ប្រើប្រាស់អ្នកស្វែងរកផែនការសុខភាពវ៉ាស៊ីងតោន គេហទំព័រឥតគិតថ្លៃ ឬ ដោយការហៅទូរស័ព្ទទៅបណ្តាញទាន់ហេតុការណ៍អំឡុងពេលម៉ោងធ្វើការ ។ អ្នកអាចទទួលបានជំនួយដោយផ្ទាល់ផងដែរ ក្នុងសហគមន៍របស់អ្នក ។

ដើម្បីដាក់ពាក្យ ឬ ដើម្បីស្វែងរកឈ្មោះរបស់មនុស្សនៅក្នុងសហគមន៍ របស់អ្នក (អ្នកស្ទង់មើលទិស) ដែលអាចជួយអ្នកដាក់ពាក្យ៖

- ចូលមើល **www.wahealthplanfinder.org** ឬ
- ហៅទូរស័ព្ទ 1-855-923-4633

## នៅពេលអ្នកដាក់ពាក្យសុំ អ្នកនឹងត្រូវការ៖

- ព័ត៌មានអំពីប្រាក់ចំណូលរបស់អ្នក អាសយដ្ឋានផ្ញើសំបុត្រ និងព័ត៌មានលម្អិតផ្សេងទៀត ។
- ប្រសិនបើអ្នកមិនមានអាសយដ្ឋានផ្ញើសំបុត្រ អ្នកអាចប្រើប្រាស់ អាសយដ្ឋានរបស់មិត្តភក្តិ ឬរបស់សាច់ញាតិ ឬអាសយដ្ឋាននៃជម្រកមនុស្សពេញវ័យ ឬសាលារៀន ។

## ហៅទូរស័ព្ទទៅលេខ 1-855-WAFINDER (855-923-4633) សម្រាប់ជំនួយ ប្រសិនបើអ្នក៖

- មិនមានព័ត៌មានដែលការដាក់ពាក្យសុំស្នើរក ។
- ស្ថិតក្រោមអាយុ 18 ឆ្នាំ ហើយអ្នកចង់ដាក់ពាក្យសុំដោយផ្ទាល់ ដោយមិនមានឪពុកម្តាយ/អាណាព្យាបាលរបស់អ្នក (អ្នកមិនអាចដាក់ពាក្យលើគេហទំព័រនេះឡើយ)